# វគ្គបំប៉នអំពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន ( SMLTC )

## គាំទ្រមូលនិធិដោយអង្គការឆាលហ្វានកម្ពុជាតាមរយៈគម្រោងភាពជាអ្នកដឹកនាំ និងគ្រប់គ្រង (SML) របស់អង្គការខេប

២០១៥ – ២០១៦

| ការរៀបចំឯកសារ ១ | ការបំប៉នគ្រូឧទ្ទេស ១ | សិក្ខាសាលាទី ១ | កិច្ចការ ១ ការរៀបចំឯកសារ ២ | ការចុះជួយនាយកសាលា ១/ការរៀបចំឯកសារ ២ | ការបំប៉នគ្រូឧទ្ទេស ២ | សិក្ខាសាលាទី ២ | កិច្ចការ ២ | ការចុះជួយនាយកសាលា ២ | ការឆ្លុះបញ្ចាំង និង វាយតម្លៃឆ្នាំទី ១ |
|---|---|---|---|---|---|---|---|---|---|
| សីហា | កញ្ញា | តុលា | វិច្ឆិកា-ធ្នូ | ធ្នូ-មករា | មករា | កុម្ភៈ | មីនា-ឧសភា | មេសា-ឧសភា | មិថុនា |

២០១៦ – ២០១៧

| ការរៀបចំឯកសារ ៣ | ការបំប៉នគ្រូឧទ្ទេស ៣ | សិក្ខាសាលាទី ៣ | កិច្ចការ ៣ ការរៀបចំឯកសារ ៤ | ការចុះជួយនាយកសាលា ៣/ការរៀបចំឯកសារ ៤ | ការបំប៉នគ្រូឧទ្ទេស ៤ | សិក្ខាសាលាទី ៤ | កិច្ចការ ៤ | ការចុះជួយនាយកសាលា ៤ | ការឆ្លុះបញ្ចាំង និង វាយតម្លៃឆ្នាំទី ២ |
|---|---|---|---|---|---|---|---|---|---|
| សីហា | កញ្ញា | តុលា | វិច្ឆិកា-ធ្នូ | ធ្នូ-មករា | មករា | កុម្ភៈ | មីនា-ឧសភា | មេសា-ឧសភា | មិថុនា |

**គោលបំណង:** ក្រោយការបញ្ចប់កម្មវិធីបំប៉ននាយកសាលារៀននឹង:

1. យល់ដឹងពីធាតុសំខាន់ៗនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងល្អ ។
2. អាចបង្ហាញបំណិនថ្មីៗក្នុងការដឹកនាំសាលារៀន ។
3. ដឹកនាំការផ្លាស់ប្តូរក្នុងសាលារៀនដើម្បីផ្តល់ការអប់រំមួយដែលល្អប្រសើរសម្រាប់កុមារ ។

### សិក្ខាសាលាទី១ ( ០២ថ្ងៃ )

**វត្ថុបំណង:**

- យល់ច្បាស់ពីអត្ថន័យនៃភាពជាអ្នកដឹកនាំ និងភាពខុសគ្នារវាងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង ។
- យល់ពីសារៈសំខាន់នៃការជឿជាក់មួយចំនួនដែលជួយកែលម្អភាពជាអ្នកដឹកនាំ: ចក្ខុវិស័យ វត្តមានបង្ហាញមុខ ទំនាក់ទំនង និងការរៀន ។
- យល់ដឹងពីសារៈសំខាន់នៃការគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ
- ចេះសម្របសម្រួលផែនការអភិវឌ្ឍសាលារៀនតាមបែប LFA

- អ្វីដែលហៅថា ភាពជាអ្នកដឹកនាំ?
- ភាពខុសគ្នារវាងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- ភាពជឿជាក់មួយចំនួនដែលនាយកសាលារៀនគួរមាន
- ភាពជឿជាក់សំខាន់ៗចំនួន៤: ចក្ខុវិស័យ វត្តមានបង្ហាញមុខ ទំនាក់ទំនង និងការរៀនពេញមួយជីវិត ។
- សកម្មភាពនាយកសាលាដែលមានជំនឿទាំងបួនខាងលើ
- ការយល់ដឹងអំពីសូចនាករសំខាន់ៗមួយចំនួន
- សមាសភាគសាលាកុមារមេត្រី
- បំណិនគ្រប់គ្រង និងធ្វើផែនការទូទៅ
- បំណិនគ្រប់គ្រងហិរញ្ញវត្ថុ
- ការធ្វើផែនការអភិវឌ្ឍសាលារៀនតាមបែបផែនការសមហេតុផល (LFA)
- ផែនការសកម្មភាពកំណែលម្អភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

### សិក្ខាសាលាទី២ ( ០២ថ្ងៃ )

**វត្ថុបំណង:**

- ក្លាយជានាយកដែលមានវត្តមានបង្ហាញមុខប្រសើរឡើង និងមានភាពដឹកនាំដើម្បីកែលម្អការបង្រៀន ។
- ក្លាយជានាយកដែលចេះលើកទឹកចិត្តបុគ្គលិកឱ្យប្រឹងប្រែងធ្វើការកាន់តែខ្លាំង និងប្រសើរឡើង ។
- ក្លាយជានាយកសាលារៀន ដែលចេះគាំទ្រគ្រូបង្រៀន និងបង្កើតបរិស្ថានសំបូរបែបក្នុងការកែលម្អការបង្រៀន និងរៀន ។

- អ្វីទៅហៅថា ភាពដឹកនាំដើម្បីកែលម្អការបង្រៀន?
- កត្តាដែលជួយសិស្សរៀនបានប្រកបដោយប្រសិទ្ធភាព
- ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ
- វិធីដែលមនុស្សរៀន/របៀបរៀនផ្សេងៗ
- កត្តាដែលធ្វើឱ្យសិស្សបាក់ទឹកចិត្ត
- អ្វីដែលនាយកសាលាអាចសង្កេតក្នុងថ្នាក់រៀន
- ការបង្កើតសំណួរដែលជួយឱ្យសិស្សគិត
- ការបង្រៀនផ្ទាល់ចំពោះថ្នាក់រៀនទាំងមូល
- ការងារក្រុមសិស្ស
- អ្វីដែលធ្វើឱ្យបរិស្ថានថ្នាក់រៀនល្អ?
- ការសង្កេតដើម្បីជួយគ្រូបង្រៀន និងផ្តល់ព័ត៌មានត្រឡប់
- កត្តាដែលធ្វើឱ្យគ្រូបាក់ទឹកចិត្ត
- ផែនការសកម្មភាពកំណែលម្អការដឹកនាំ និងគ្រប់គ្រង

### សិក្ខាសាលាទី៣ ( ០២ថ្ងៃ )

**វត្ថុបំណង:**

- ក្លាយជានាយកដែលមានវត្តមានបង្ហាញមុខកាន់តែប្រសើរឡើង និងមានភាពដឹកនាំដើម្បីកែលម្អការបង្រៀន ។
- ក្លាយជានាយកដែលមានឆន្ទៈ ច្នៃប្រឌិត និង ហ៊ានប្រថុយ ។
- ក្លាយជានាយកដែលមានជំនាញសម្របសម្រួលការប្រជុំក្រុមបច្ចេកទេសយ៉ាងប្រសើរ ។
- ក្លាយជានាយកសាលាដែលចេះប្រើទិន្នន័យសម្រាប់វាយតម្លៃប្រសិទ្ធភាពនៃផែនការអភិវឌ្ឍសាលារៀន ។

- ហេតុអ្វីបានជាចក្ខុវិស័យសំខាន់?
- ការធ្វើផែនការដើម្បីធ្វើឱ្យបានសម្រេចចក្ខុវិស័យ
- គំនិតច្នៃប្រឌិត និងការហ៊ានប្រថុយ
- ប្រភេទនៃអំណាច
- សកម្មភាពក្នុងថ្នាក់រៀនដែលទ្រទ្រង់ការរៀនរបស់សិស្ស
- ការយល់ដឹងបន្ថែមអំពីការគិតកម្រិតខ្ពស់
- ការសង្កេតថ្នាក់រៀនដើម្បីជួយគ្រូ
- ការផ្តល់ព័ត៌មានត្រឡប់
- ពាក្យ និងល្បះដែលជំរុញទឹកចិត្តគ្រូ
- ការយល់ដឹងពីវិធីជំរុញទឹកចិត្តគ្រូដើម្បីឱ្យក្លាយជាគ្រូកាន់តែល្អឡើង
- ការប្រជុំក្រុមបច្ចេកទេសក្នុងប្រទេសកម្ពុជា
- ផែនការសកម្មភាពកំណែលម្អភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

### សិក្ខាសាលាទី៤ ( ០២ថ្ងៃ )

**វត្ថុបំណង:**

- យល់ដឹងកាន់ស៊ីជម្រៅលើមេរៀន និងបំណិនក្នុងសិក្ខាសាលាភាពជាអ្នកដឹកនាំ និងគ្រប់គ្រងទី១, ២ និង៣ ។
- មានសមត្ថភាពកំណត់រកវិធីជាក់ស្តែងដើម្បីយកខ្លឹមសារដែលបានរៀនទៅអនុវត្តឱ្យស្របទៅនឹងស្ថានភាពសាលារៀន ។
- យល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់នៃការជំរុញឱ្យសិស្សមានការគិតបែបវិភាគ ច្នៃប្រឌិត ដើម្បីលើកកម្ពស់ការអប់រំក្នុងប្រទេសកម្ពុជា ។

- សារៈសំខាន់នៃការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៏
- នាយកសាលារៀនជាគំរូ និងជាប្រធានអ្នករៀន
- នាយកសាលារៀនត្រូវមានវត្តមានបង្ហាញមុខក្នុងសាលារៀន និងសហគមន៏
- ការកែលម្អទំនាក់ទំនង: សិស្ស មាតាបិតា គ្រូបង្រៀន និងសហគមន៍
- ការវិភាគទិន្នន័យដើម្បីកែលម្អការរៀនរបស់សិស្ស
- ការជួយសិស្សឱ្យមានការគិតកម្រិតខ្ពស់
- ការកែលម្អបំណិនសួរសំណួររបស់គ្រូ
- ជំហានប្រាំនៃការបង្រៀន: ការរៀបចំថ្នាក់ឬទំនាក់ទំនង ការរំឭកមេរៀនចាស់ ការបង្រៀនមេរៀនថ្មី ការពង្រឹងមេរៀន បណ្តាំផ្ញើឬការងារផ្ទះ
- ការប្រជុំក្រុមបច្ចេកទេសដើម្បីបង្រៀនអំពីវិធីបង្រៀន និងរៀនថ្មីៗ
- ការចុះជួយគាំទ្រតាមថ្នាក់រៀនដើម្បីបង្រៀនពីវិធីថ្មីៗដល់គ្រូ
- ការត្រួតពិនិត្យឡើងវិញពីចំណេះដឹង និងបំណិនគ្រប់គ្រង
- ផែនការសកម្មភាពកំណែលម្អភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

*គ្រប់អ្នកដឹកនាំអប់រំមានសិទ្ធិ និងការទទួលខុសត្រូវក្នុងការគិតដោយច្នៃប្រឌិត និងការហ៊ានប្រថុយ*

*ឯកសារបំប៉នត្រូវបានកែសម្រួលពីគម្រោង CESSP និង IBEC*

# គម្រោង ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន

# School Management and Leadership (SML) Project

## គោលបំណងគម្រោង

សាលាគោលដៅទាំងអស់ទទួលបានការរីកចម្រើន ផ្នែកសាលាកុមារមេត្រី ដោយសារការដឹកនាំ និងគ្រប់គ្រងកាន់តែប្រសើរឡើងរបស់នាយកសាលារៀន។

## គោលដៅ និង រយ:ពេល

- ១១សាលារៀន ក្នុងស្រុកឆ្លូង ខេត្តក្រចេះ
- សិស្សសរុបចំនួន ៣៦៥៧ នាក់ (ស្រី១៨៥៤នាក់) ចាប់ពីថ្នាក់ទី១ ដល់ទី៦
- អ្នកអនុវត្តផ្ទាល់មានចំនួន ១៩៤នាក់ (ស្រី ៧៩នាក់)
- គម្រោងចាប់ផ្តើមពីថ្ងៃទី០១ សីហា ២០១៥ ដល់ ថ្ងៃទី ៣០មិថុនា ឆ្នាំ២០១៨

## មូលហេតុនៃការបង្កើតគម្រោង

- នាយកសាលាភាគច្រើនមិនទាន់ទទួលបានការបំប៉ន អំពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- សាលារៀនមិនទាន់មានលក្ខណ:ជាសាលាកុមារមេត្រីល្អប្រសើរនៅឡើយ
- នាយកសាលាភាគច្រើនមិនទាន់យល់ពីការដឹកនាំផែនការអភិវឌ្ឍសាលារៀន
- ការទំនាក់ទំនង និងការចូលរួមរវាងសាលារៀន និងសហគមន៍ មាតាបិតា និងអាជ្ញាធរមូលដ្ឋាននៅមានកម្រិត
- មិនមានការអនុវត្តកម្មវិធីបំណិនជីវិតដែលជាផ្នែកមួយ នៃកម្មវិធីសាលាកុមារមេត្រី
- នាយកសាលាភាគច្រើនមិនបានសង្កេតថ្នាក់រៀនដើម្បីគាំទ្រការបង្រៀន និងរៀន

## វត្ថុបំណងគម្រោង

- លើកកម្ពស់បំណិនបច្ចេកទេសរបស់ក្រុមបំប៉ននិងពិនិត្យតាមដាន (DTMT) ដើម្បីផ្តល់ការបំប៉នដល់នាយកសាលា
- កែលម្អសមត្ថភាពនាយកសាលាតាមរយ:ការកសាងសមត្ថភាព
- កែលម្អបរិស្ថានសាលាកុមាមេត្រីតាមរយ:ការពង្រឹងសមត្ថភាពនាយកសាលា និងការផ្តល់កញ្ចប់ជំនួយ
- លើកកម្ពស់សមត្ថភាពគណ:កម្មការទ្រទ្រង់សាលាដើម្បីចូលរួម ត្រួតពិនិត្យ និងគ្រប់គ្រងធនធាន ។

## វិធីសាស្ត្របច្ចេកទេស

- កសាងសមត្ថភាពតាមរយ: ការបំប៉ន
- ការអភិវឌ្ឍដោយប្រើសកម្មភាពចម្រុះ
- ការអភិវឌ្ឍដែលដឹកនាំដោយអ្នកពាក់ព័ន្ធ និងកសាងអំណាចមូលដ្ឋានតាមរយ:ការប្រើបញ្ញើសកម្មភាព
- ការចាត់ថ្នាក់សាលារៀនទៅតាមកម្រិតអភិវឌ្ឍ



## សកម្មភាពសំខាន់ៗរបស់គម្រោង

### ១. លើកកម្ពស់បំណិនបច្ចេកទេសរបស់ក្រុមបំប៉ន និង ពិនិត្យ តាមដាន (DTMT) ដើម្បីផ្តល់ការបំប៉នដល់នាយកសាលា

- បង្កើតឧបករណ៍វាយតម្លៃក្រុម DTMT ដើម្បីកំណត់រកខ្លឹមសារសកម្ម-ភាពបំប៉នពួកគាត់បន្ថែម
- បំប៉នវគ្គគ្រូឧទ្ទេសដល់ក្រុម DTMT អំពីភាពជាអ្នកដឹកនាំ និងការគ្រប់-គ្រងដើម្បីពួកគាត់បំប៉នបន្តដល់នាយកសាលាដោយសហការជាមួយមន្ត្រីគម្រោង
- រៀបចំប្រជុំប្រចាំឆ្នាំដើម្បីត្រួតពិនិត្យពីដំណើរការគម្រោងដោយប្រើប្រាស់សៀវភៅបញ្ហា និងដំណោះស្រាយ
- បំប៉នវគ្គគ្រូឧទ្ទេសដល់ក្រុម DTMT ពីរបៀបវាយតម្លៃកិច្ចការរបស់នាយកការផ្តល់ព័ត៌មានត្រឡប់ និងការបំពេញរបាយការណ៍ពិនិត្យតាមដាន
- ក្រុម DTMT រៀបចំប្រជុំប្រចាំត្រីមាសដើម្បីត្រួតពិនិត្យគំហើញ និងធ្វើផែនការសកម្មភាពសម្រាប់ត្រីមាសបន្ទាប់

### ២. កែលម្អសមត្ថភាពនាយកសាលាតាមរយ:ការកសាងសមត្ថភាព

- មន្ត្រីគម្រោង និង ក្រុម DTMT រៀបចំផែនការបំប៉ននាយកសាលាអំពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- ផ្តល់សិក្ខាសាលាភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដល់នាយកសាលារៀន
- ធ្វើផែនការទស្សនកិច្ចសិក្សាសម្រាប់នាយកសាលារៀន និង ក្រុម DTMT
- សម្របសម្រួលដំណើរទស្សនកិច្ចសិក្សាសម្រាប់នាយកសាលា និងក្រុម DTMT ទៅកាន់សាលាកុមារមេត្រីគំរូ
- ត្រួតពិនិត្យតាមដានការអនុវត្តកិច្ចការរបស់នាយកសាលា ដែលបានដាក់ជូនពិនិត្យពិន្ទុ និងប្រគល់ជូនសញ្ញាបត្រ

### ៣. កែលម្អបរិស្ថានសាលាកុមាមេត្រីតាមរយ:ការពង្រឹងសមត្ថភាពនាយកសាលា និងការផ្តល់កញ្ចប់ជំនួយ

- ក្រុម DTMTs នាយកសាលា និងប្រធានក្រុមបច្ចេកទេសរៀបចំការប្រជុំបច្ចេកទេសប្រចាំខែ
- សម្របសម្រួលការប្រជុំបច្ចេកទេសដោយផ្តោតលើការបង្រៀន និងរៀន
- បំប៉នគ្រូអំពីសម្ភារ:អំណាន និងគណិតវិទ្យា
- ការចាត់ថ្នាក់សាលារៀនទៅតាមកម្រិតអភិវឌ្ឍ
- សាលារៀនបង្កើតផែនការអភវិឌ្ឍ
- បំប៉ននាយកសាលារៀន និងប្រធានគណ:កម្មការទ្រទ្រង់សាលារៀនអំពីការបើក និងទូទាត់ថវិកាជំនួយ
- សាលារៀនអនុវត្តសកម្មភាពដែលមានក្នុងផែនការអភិវឌ្ឍដោយមានការគាំទ្រពី អង្គការខេប និងឆាលហ្វាន

### ៤. លើកកម្ពស់សមត្ថភាពគណ:កម្មការទ្រទ្រង់សាលាដើម្បីចូលរួមត្រួតពិនិត្យ និងគ្រប់គ្រងធនធាន ។

- មន្ត្រីគម្រោង ក្រុម DTMT និងនាយកសាលារៀនរៀបចំផែនការបំប៉នគណ:កម្មការទ្រទ្រង់សាលារៀនផ្អែកលើលទ្ធផលវាយតម្លៃ
- សម្របសម្រួលសិក្ខាសាលាដល់គណ:កម្មការទ្រទ្រង់សាលារៀន
- បង្កើតឧបករណ៍វាយតម្លៃគណ:កម្មការទ្រទ្រង់សាលារៀន
- ចុះវាយតម្លៃគណ:កម្មការទ្រទ្រង់សាលារៀន ដើម្បីរកទិន្នន័យដើម (baseline) ទិន្នន័យពាក់កណ្តាលគម្រោង (midline) និងទិន្នន័យចុងក្រោយ (endline)
- ផ្តល់ព័ត៌មានត្រឡប់ និងការកសាងសមត្ថភាពគណ:កម្មការទ្រទ្រង់សាលា

គាំទ្រមូលនិធិដោយ ChildFund Cambodia

ប្រតិបត្តិដោយ

ក្នុងកិច្ចសហការជាមួយ